ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ៣៦៣ ទសណ.អកទ

ថ្ងៃ សៅរ៍ ៣ កើត ខែ ជេស្ឋ ឆ្នាំ កុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពីការសម្រួលការធ្វើដំណើររបស់ភ្ញៀវទេសចរនិងអ្នកដំណើរ នៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស

ក្រសួងទេសចរណ៍មានកិត្តិយសសូមជម្រាបជូនដំណឹងជាថ្មីម្តងទៀតដល់ប្រតិបត្តិករទេសចរណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជាមេត្តាជ្រាបថា ក្នុងគោលបំណងដើម្បីសម្រួលការធ្វើដំណើរនិងកាត់បន្ថយរបាំងមិនចាំបាច់ដល់ភ្ញៀវទេសចរអន្តរជាតិចូលមកទស្សនាព្រះរាជាណាចក្រកម្ពុជា ក្រសួងទេសចរណ៍បានសហការជាមួយក្រសួងមហាផ្ទៃ (អគ្គនាយកដ្ឋានអន្តោប្រវេសន៍) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា) ក្នុងការសម្រួលបែបបទនៃការធ្វើដំណើរមួយចំនួន ដូចខាងក្រោម:

១. អំពីសាលាកបត្រចូល ចេញប្រទេសនិងបែបបទស្នើសុំទិដ្ឋាការ

- បែបបទនៃការបំពេញសាលាកបត្រចូល ចេញ និងស្នើសុំទិដ្ឋាការពេលមកដល់ត្រូវបានបញ្ចូលគ្នាតែមួយសន្លឹក ដោយមានជាភាសាខ្មែរ ចិន និងអង់គ្លេស
- ភ្ញៀវទេសចរបំពេញបែបបទចូលតែម្តងគត់ ហើយពេលត្រឡប់ចេញទៅវិញមិនតម្រូវឲ្យបំពេញបែបបទទៀតទេ និងមិនត្រូវការរូបថតឡើយ
- ចំពោះពលរដ្ឋខ្មែរដែលធ្វើដំណើរចេញនិងចូលប្រទេសដែលកាន់លិខិតឆ្លងដែនអេឡិចត្រូនិចខ្មែរ (E-Passport) មិនតម្រូវឲ្យបំពេញបែបបទទេ។

២. អំពីបែបបទចូល ចេញតាមច្រកទ្វារព្រំដែនអន្តរជាតិ

- ភ្ញៀវទេសចរដែលបើកបរដោយខ្លួនឯង (Self Driving Tours) មានបំណងចូលមកទស្សនាព្រះរាជាណាចក្រកម្ពុជាដោយប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួននាំចូលបណ្តោះអាសន្ន និងចេញទៅវិញតាមច្រកទ្វារព្រំដែនអន្តរជាតិនានាទូទាំងប្រទេស អាចបំពេញប្រតិវេទន៍គយសង្ខេបសម្រាប់មធ្យោបាយធ្វើដំណើរចូល-ចេញបណ្តោះអាសន្នរបស់ភ្ញៀវទេសចរ (Summary declaration form for temporary entry-exit of conveyance of tourists) ជាមួយមន្ត្រីគយនៅតាមច្រកទ្វារតែម្តង
- ភ្ញៀវទេសចរមិនចាំបាច់បង់ប្រាក់និម្មិត្តធានា (Deposit) និងថ្លៃធានារ៉ាប់រងឡើយ
- ភ្ញៀវទេសចរអាចចូលគេហទំព័រ www.customs.gov.kh ដើម្បីទទួលយកព័ត៌មានលំអិតបន្ថែមទៀត។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមប្រតិបត្តិករទេសចរណ៍ទាំងអស់មេត្តាជ្រាបនិងជួយផ្សព្វផ្សាយបន្តឲ្យបានទូលំទូលាយ តាមការគួរ។

សូមអរគុណ!

អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

# ព្រះរាជាណាចក្រកម្ពុជា

# 柬埔寨王国

# KINGDOM OF CAMBODIA



## CAMBODIA

*Kingdom of Wonder*

សលាកប័ត្រអន្តោប្រវេសន៍

移民卡

**IMMIGRATION CARD**

**www.immigratin.gov.kh**

# សាលាកប័ត្រអន្តោប្រវេសន៍ / 移民卡 / IMMIGRATION CARD

សូមបំពេញជាអក្សរឡាតាំង / 请用英文写成大写字母 / PLEASE COMPLETE IN CAPITAL LETTERS

គោត្តនាម
姓氏 / Surname

ភេទ / 性别 / Gender

ប្រុស / 男 / M ☐

ស្រី / 女 / F ☐

នាម / 名字
Given Name

ថ្ងៃ/ខែ/ឆ្នាំកំណើត
出生日期 / Date of Birth DD / MM / YY

សញ្ជាតិ / 国籍
Nationality

លិខិតឆ្លងដែន/ឯកសារធ្វើដំណើរលេខ
护照/旅遊證件號碼 / Passport Nº

មធ្យោបាយធ្វើដំណើរលេខ
航班号 / Flight/Car/Ship/Train Nº

មកពី
来自/From

ទីក្រុងចុងក្រោយ
最後的城市 / Final City

គោលបំណងធ្វើដំណើរ
旅行目的 / Purpose of Travel

រយៈពេលស្នាក់នៅ
逗留时间 / Length of Stay

សូមជ្រើសប្រភេទទិដ្ឋាការបើអ្នកត្រូវស្នើសុំ/如果需要，请选择签證類型/ Please Choose a Visa Type if required

☐ ទិដ្ឋាការទេសចរណ៍ /旅游签证 / Tourist Visa

☐ ទិដ្ឋាការពិសេស/特殊签证/Special Visa (Khmer Origin Only)

☐ ទិដ្ឋាការធម្មតា/普通签证/ Ordinary Visa

☐ ទិដ្ឋាការផ្សេងៗ /其他签证/ Other Visa......................

លេខទិដ្ឋាការ ( បើមាន ) / 签证號码(如果可用) /Visa Nº (if available)

ទូរស័ព្ទ/អ៊ីម៉ែល/电话号码/电邮
Telephone Nº /Email

អាសយដ្ឋាននៅកម្ពុជា
地址在柬埔寨/Address in Cambodia

ខ្ញុំសូមធានាអះអាងថាព័ត៌មានដែលបានបំពេញខាងលើគឺត្រឹមត្រូវពិតប្រាកដមែន ។

我聲明, 本表中提供的信息是完整和正确。

***I declare that the information given on this form is complete and correct.***

***សម្រាប់សមត្ថកិច្ច / 仅官方使用/ FOR OFFICIAL USE***

កាលបរិច្ឆេទ / 日期/ Date.....DD./.MM./..YY...

ហត្ថលេខា/ 日期 /Signature